**សុន្ទរកថាបិទ**

**ឯកឧត្តម ពេជ្រ ប៊ុនធិន រដ្ឋមន្ត្រី ក្រសួងមុខងារសាធារណៈ និងជា ប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ**

**ថ្លែងក្នុងអង្គសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ**

**សាលាភូមិន្ទរដ្ឋបាល ថ្ងៃទី ០៩-១០ ខែ មីនា ឆ្នាំ ២០១៧**

- *ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ថ្នាក់ដឹកនាំក្រសួងមុខងារសាធារណៈ តំណាងក្រសួង ស្ថាប័ន រាជធានី ខេត្ត អស់លោក លោកស្រី អ្នកនាង កញ្ញា ទាំងអស់ដែលមានវត្តមាននៅថ្ងៃនេះ ជាទីស្រលាញ់រាប់អាន!*

នារសៀលថ្ងៃនេះ ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ដែលបានចូលរួមជាមួយ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកកញ្ញាក្នុងកម្មវិធីបិទអង្គសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ។ ខ្ញុំមានសេចក្ដីរំភើបរីករាយណាស់ដែលអង្គសន្និបាតបានដំណើការរយៈពេលពីរថ្ងៃពេញតាមកម្មវិធីគ្រោងទុក និងទទួលបានលទ្ធផជាទីពេញចិត្ត។ ជាមួយគ្នានេះដែរ ខ្ញុំក៏សូមអរគុណដល់ឯកឧត្តម **រស់ សុផាន់** រដ្ឋលេខាធិការនៃក្រសួងមុខងារសាធារណៈ ដែលបានរាយការណ៍ យ៉ាងក្បោះក្បាយប្រកបដោយលទ្ធផលជាវិជ្ជមាននៃអង្គសន្និបាតរបស់យើងរយៈពេលពីរថ្ងៃកន្លងមកនេះ។

ខ្ញុំសូមយកឱកាសនេះផងដែរថ្លែងអំណរគុណចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញាដែលបានចូលរួមក្នុងអង្គសន្និបាត និងក្រុមការងាររបស់ក្រសួងមុខងារ សាធារណៈបានរៀបចំអង្គសន្និបាតយ៉ាងយកចិត្តទុកដាក់។ ជាពិសេសខ្ញុំសូមកោត

សរសើរចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលបានខិតខំប្រឹងប្រែងតាមតួនាទី និងភារកិច្ចរបស់ខ្លួនរួមចំណែកធ្វើឱ្យក្រសួងមុខងារសាធារណៈ សម្រេចបានសមិទ្ធផលជាច្រើនដូចមានក្នុងរបាយការណ៍ជាក់ជូនអង្គសន្និបាត។

តាមរបាយការណ៍បូកសរុបរបស់អង្គសន្និបាត ក៏ដូចជាបទអន្តាគមន៍នានា យើងអាចវាយតម្លៃបានថា ក្នុងរយៈពេល១២ខែកន្លងមកនេះ ក្រសួងមុខងារសាធារណៈ គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងក្រុមការងារកែទម្រង់ប្រព័ន្ធបៀវត្ស ពិតជាសម្រេចបាននូវសមិទ្ធផលជាច្រើនដែលឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។ សមិទ្ធផលទាំងនេះបានមកដោយសារការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ទាំងក្នុងកម្រិតគ្រប់គ្រង និងក្នុងកម្រិតបច្ចេកទេស ជាពិសេស ការសម្របសម្រួល និងកិច្ចសហការយ៉ាងល្អពីគ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងលេខាធិការដ្ឋាននៃកម្មវិធីកែទម្រង់ទាំង៣ រួមជាមួយនិងដៃគូអភិវឌ្ឍក្នុងក្រុមការងារបច្ចេកទេសរដ្ឋបាលសាធារណៈ។

- *ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !*

ភាពជោគជ័យនេះ បានបញ្ជាក់ពីភាពជាអ្នកដឹកនាំ និងសមត្ថភាពសម្របសម្រួលរបស់ថ្នាក់ដឹកនាំ និងសមត្ថភាពជំនាញវិជ្ជាជីវៈរបស់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងមុខងារសាធារណៈក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។ តែទោះជាយ៉ាងណាក៏ដោយ យើងនៅមានការងារដែលត្រូវអនុវត្តចំពោះមុខ ពិតជាជួបនូវការលំបាក និងបញ្ហាប្រឈមជាច្រើន ដែលទាមទារឱ្យយើងទាំងអស់គ្នាបន្តកិច្ចខិតខំប្រឹងប្រែងអនុវត្ត សហការគ្នា សាមគ្គីគ្នា និងធ្វើការជាក្រុមក្នុងស្មារតីបុរេសកម្ម និងការទទួលខុសត្រូវរៀងៗខ្លួន។ បញ្ហាប្រឈមដែលជួបប្រទះនាពេលកន្លងមក ដែលទាមទារឱ្យមានការដោះ ស្រាយជាបន្ទាន់ ក្នុងនោះរួមមាន៖

១. ការសម្របសម្រួលការអនុវត្តការងារទាំងកម្រិតផ្ទៃក្នុងក្រសួង និងក្រសួងស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅមានកម្រិត

២. សមត្ថភាពនៅក្នុងការចូលរួមអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈនៅមានកម្រិត ដែលទាមទារឱ្យមានការអភិវឌ្ឍសមត្ថភាព និងចំណេះដឹងអំពីការងារកែទម្រង់រដ្ឋបាល

សាធារណៈ ជាពិសេស មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ដែលជាសេនាធិការឱ្យគណៈអភិបាលរាជធានី ខេត្ត

៣. ការងារកែទម្រង់រដ្ឋបាលសាធារណៈមិនទាន់បានត្រូវដាក់បញ្ចូលទាំងស្រុងទៅក្នុងផែនការសកម្មភាពប្រចាំខែ ត្រីមាស ឆមាស ដែលត្រូវអនុវត្តដោយក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

៤. ការងារកែទម្រង់រដ្ឋបាលសាធារណៈ គឺជាការងាររបស់យើងទាំងអស់គ្នាមិនមែនជាការងាររបស់អ្នកណាមួយ ឬអង្គភាពណាមួយនោះឡើយ ដែលទាមទារឱ្យមានការចូលរួមគ្រប់កម្រិតទាំងថ្នាក់ដឹកនាំ អ្នកគ្រប់គ្រង និងមន្ត្រីរាជការទាំងអស់នៃក្រសួងមុខងារសាធារណៈ

៥. ផែនការសកម្មភាពរបស់លេខាធិការដ្ឋានកែទម្រង់ទាំងបី(PAR, D&Dនិង PFM) បានបង្កើតផែនការសកម្មភាពរួមគ្នា ប៉ុន្តែកម្រិតនៃការអនុវត្តនៅមានលក្ខណៈផ្សេងគ្នា ដោយហេតុថា ជំនួយពីដៃគូអភិវឌ្ឍបានជួយគាំទ្រដល់ការងារកែទម្រង់រដ្ឋបាលសាធារណៈនៅមានកម្រិតតិចតួច បើធៀបទៅនឹងជំនួយដល់ការងារកែទម្រង់ PFM និង D&D ដូចនេះនាំឱ្យការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ត្រូវអនុវត្តទៅតាមកម្រិតលទ្ធភាពនៃថវិកា ជាតិ។

- *ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !*

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមបញ្ជាក់ថា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានបញ្ជាក់យ៉ាងច្បាស់នៅក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់ទី៣ ដែលបង្ហាញពីការប្តេជ្ញាចិត្តផ្នែកនយោបាយរបស់រាជរដ្ឋាភិបាល និងជាការតម្រង់ទិសសម្រាប់ការដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិស័យមុខងារសាធារណៈ និងការកែទម្រង់រដ្ឋបាលសាធារណៈ។ ដូច្នេះ កត្តាជោគជ័យលើការងារទាំងនេះគឺស្ថិតនៅលើការទទួលខុសត្រូវរបស់យើងទាំងអស់គ្នាក្នុងការបំពេញភារកិច្ចរៀងៗខ្លួនប្រកប ដោយមនសិការវិជ្ជាជីវៈ ភក្តីភាព ឆន្ទៈម្ចាស់ការ និងវប្បធម៌សេវាសាធារណៈក្នុងការកែប្រែខ្លួនឱ្យទៅជាអ្នកបម្រើសេវា និងជាដៃគូដែលគួរឱ្យជឿទុកចិត្តបានសំដៅបម្រើប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង។

ជាមួយគ្នានេះដែរ ខ្ញុំសូមផ្តល់មតិផ្តាំផ្ញើមួយចំនួនបន្ថែមទៀតជាទិសដៅសម្រាប់ការងារឆ្នាំ២០១៧ និងឆ្នាំបន្ត ក្នុងនោះរួមមាន៖

ទី១- បន្តរៀបចំធ្វើវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការរៀបចំអង្គវិជ្ជាជីវៈ ការកំណត់មុខតំណែង ការពិពណ៌នាមុខតំណែង ដើម្បីផ្តល់លទ្ធភាពឱ្យក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជ្រើសរើស និងប្រើប្រាស់ធនធានមនុស្សឱ្យចំទិសដៅ ទីកន្លែងដែលត្រូវការ

ទី២- បណ្តុះបណ្តាលសមត្ថភាពមន្ត្រីរាជការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យមានលក្ខណៈជាប្រព័ន្ធស្របតាមសេចក្តីត្រូវការនៃការអនុវត្តគោលនយោបាយ និងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ក្នុងនោះត្រូវមានការយកចិត្តទុកដាក់ពង្រឹងបន្ថែមតួនាទីរបស់សាលាភូមិន្ទរដ្ឋបាលឱ្យកាន់តែសកម្មក្នុងការបណ្តុះបណ្តាល ព្រមទាំងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីរាជការកម្រិតគ្រប់គ្រងជាន់ខ្ពស់ ជាពិសេស ថ្នាក់ដឹកនាំ និងមន្ត្រីរាជការជាស្ត្រី

ទី៣- ជំរុញការផ្តល់សេវាសាធារណៈ ផ្អែកលើគោលនយោបាយ និងស្តង់ដាសេវាសាធារណៈច្បាស់លាស់ ប្រព័ន្ធត្រួតពិនិត្យគុណភាពនិងប្រសិទ្ធភាព និងយន្តការស្ថាប័នសម្រាប់ទទួលបណ្តឹងតវ៉ា និងព័ត៌មានត្រឡប់ពីអ្នកប្រើប្រាស់សេវា ដើម្បីឲ្យឆ្លើយតបទៅនឹងសេចក្តីត្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ

ទី៤- អនុវត្តសកម្មភាពកែទម្រង់ឱ្យបានសម្រេចបានតាមសូចនាករគោលនៃសមិទ្ធកម្មដែលមានកំណត់នៅក្នុងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨

ទី៥-រៀបចំផែនការប្រើប្រាស់ធនធានមនុស្សក្នុងមុខងារសាធារណៈឱ្យបានគ្រប់ជ្រុងជ្រោយ ព្រមទាំងការត្រៀមដាក់ចេញនូវវិធានការគាំទ្រផ្សេងៗចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៨ ដើម្បីសម្រេចគោលដៅ ក្នុងការផ្តល់ជូនមន្ត្រីរាជការនូវបៀវត្សទាបបំផុត ១ លានរៀលក្នុង១ខែនៅឆ្នាំ២០១៨

ទី៦- ពង្រឹង និងពង្រីកការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យាឱ្យបានទូលំទូលាយ ដើម្បីគាំទ្រដល់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ទី៧- ចូលរួមគាំទ្រការធ្វើប្រតិភូកម្មមុខងាររបស់ក្រសួង ស្ថាប័នថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈ ការពង្រឹងសមត្ថភាពការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅថ្នាក់ក្រោមជាតិ

ទី៨- ជំរុញការដាក់ឱ្យដំណើរប្រព័ន្ធគ្រប់គ្រងគុណផលនិងប្រព័ន្ធលើកទឹកចិត្តសម្រាប់មន្ត្រីរាជការ និងស្ថាប័ន

ទី៩- រៀបចំប្រព័ន្ធបៀវត្សឱ្យមានលក្ខណៈសង្គតិភាពរវាងបៀវត្សមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ និងបន្តបង្កើនបៀវត្សមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ និងនិវត្តន៍ជនទៅតាមលទ្ធភាពទ្រទ្រង់បាននៃថវិកាជាតិ

ទី១០- ត្រូវជំរុញ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍនានាក៏ដូចជាបណ្តាប្រទេសក្នុងតំបន់អាស៊ាន លើការលើកកម្ពស់វិស័យមុខងារសាធារណៈ និងអភិវឌ្ឍវិស័យមុខងារសាធារណៈស្របតាមបរិបទកម្ពុជានីយកម្ម

ទី១១- ត្រូវមានសាមគ្គីភាព កិច្ចសហការ អនុវត្តការងារតាមមុខងារ និងតួនាទីភារកិច្ចរបស់ខ្លួនប្រកាន់ភ្ជាប់នូវវប្បធម៌សេវាសាធារណៈ ភក្តីភាព ឆន្ទៈម្ចាស់ សីលធម៌វិជ្ជាជីវៈ

ទី១២- ពង្រឹងសមត្ថភាពមន្ត្រីរាជការគ្រប់លំដ្ឋាក់នៃក្រសួងមុខងារសាធារណៈតាមរយៈការរៀបចំឱ្យមានវគ្គបណ្តុះបណ្តាល និងការចែករំលែកបទពិសោធន៍ ដើម្បីបង្កើតនូវវប្បធម៌ចែករំលែកចំណេះដឹង ចំណេះធ្វើ សំដៅលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងផលិតភាពការងារ។

- *ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !*

ជាទីបញ្ចប់ ក្នុងនាមក្រសួងមុខងារសាធារណៈ និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងអង្គសន្និបាតនាថ្ងៃនេះ។ ខ្ញុំមានក្តីសង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា នឹងចូលរួមសហការ អនុវត្តរួមគ្នា ដើម្បីសម្រេចទិសដៅការងារឆ្នាំ២០១៧ និងឆ្នាំបន្តទៅមុខទៀត។ ខ្ញុំបួងសួងដល់វត្ថុស័ក្តសិទ្ធិទាំងអស់ក្នុងលោក និងទេវតាឆ្នាំថ្មីជូនពរជ័យមហាប្រសើរជូនដល់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ឱ្យសម្រេចជោគជ័យគ្រប់ការងារ និងជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**ខ្ញុំសូមប្រកាសបិទអង្គសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧ ចាប់ពីពេលនេះតទៅ។**

**សូមអរគុណ!**